Public Disclosure Authorized

Public Disclosure Authorized

31081

កម្ពុជា

ធនាគារពិភពលោក

ព្រឹត្តិបត្រព័ត៌មាន



ឆ្នាំទី ២ លេខ ៥ ខែ ឧសភា ឆ្នាំ ២០០៤

# ដាក់រដ្ឋាភិបាលអោយនៅក្បែរដៃរបស់ប្រជាជន

អភិបាលកិច្ចជាគន្លឹះសំខាន់មួយក្នុងឯកសារយុទ្ធសាស្ត្រជំនួយសំរាប់ប្រទេសកម្ពុជា។ សំរាប់លេខនេះ ព្រឹត្តិបត្រព័ត៌មានយើងមានកិត្តិយសបានការអនុញ្ញាតិអោយជួបសំភាសន៍ជាមួយ លោកស្រី លូ ស្ដូវា ប្រធានគំរោងវិនិយោគទុនជនបទ និងអភិបាលកិច្ចមូលដ្ឋាន ស្ដីអំពីគំរោង និងសារៈសំខាន់នៃវិមជ្ឈការនៅកម្ពុជា។



*"ដោយសារប្រជាជនកម្ពុជាភាគច្រើនរស់នៅជនបទ គាត់ដឹងរឿងរ៉ាវជនបទច្រើន"*

*សំនួរៈ លោកស្រីធ្វើការទាក់ទងទៅនឹងវិមជ្ឈការនៃអភិបាលកិច្ច។ តើលោកស្រីអាចពន្យល់អំពីការងារនេះបានទេ?*

ចំលើយៈ វិមជ្ឈការនៅកម្ពុជា មានន័យថាគឺធ្វើប្រតិភូកម្ម(ផ្ទេរ) អំណាចនយោបាយពីរដ្ឋាភិបាល ថ្នាក់ជាតិទៅរដ្ឋាភិបាលថ្នាក់មូលដ្ឋានដែលបានបោះឆ្នោតថ្នាក់ឃុំនាឆ្នាំ ២០០២។ ចំនួន ឃុំ និងសង្កាត់ទាំងអស់មាន ១៦២១ ហើយមាន អាណត្តិ ៥ ឆ្នាំ។ វាជាលើកទីមួយ

*តទៅទំព័រទី ២*

# បុគ្គលិកធនាគារពិភពលោកទទួលការបណ្តុះបណ្តាលអំពីជំងឺអេដស៍

វគ្គបណ្តុះបណ្តាលស្តីអំពីការឆ្លងរាលដាលនៃជំងឺអេដស៍ រយះពេលកន្លះថ្ងៃមួយបានប្រព្រឹត្តនាដើមខែឧសភានេះ ដើម្បីផ្តល់ការយល់ដឹងដល់បុគ្គលិក និងក្រុមគ្រួសាររបស់ធនាគារពិភពលោក។ វគ្គបណ្តុះណ្តាលនេះផ្តល់ដោយអង្គការខានណាដែល ជាអង្គការសម្ព័ន្ធភាពជំងឺអេដស៍នៅកម្ពុជា។

វគ្គបណ្តុះបណ្តាលនេះបានលើកយកប្រធានបទមួយចំនួនដូចជា ស្ថានភាពទូទៅនៃជំងឺអេដស៍ ការឆ្លងរាលដាលជំងឺអេដស៍ កត្តាប្រថុយថាន និងផលប៉ះពាល់របស់វា ការប្រើប្រាស់ស្រោមអនាម័យ និងការស្ម័គ្រចិត្តពិគ្រោះយោបល់ក្នុងការធ្វើតេសឈាម និងការថែទាំ។

លោក បេង ស៊ីមេត មន្ត្រីអភិវឌ្ឍន៍ធនធានមនុស្ស និងជាប្រធានក្រុមការងារជំងឺអេដស៍ ប្រចាំការិយាល័យធនាគារពិភពលោកនៅកម្ពុជា មានប្រសាសន៍ថាការបណ្តុះបណ្តាលនេះប្រព្រឹត្តឡើងបន្ទាប់ពីចំលើយរបស់បុគ្គលិករបស់ធនាគារពិភពលោក មានលក្ខណៈខុសគ្នានៅក្នុងការសិក្សាមួយលើការយល់ដឹងអំពីជំងឺអេដស៍។

លោកមានប្រសាសន៍ថា "ការបណ្តុះបណ្តាលនេះ មានសារសំខាន់ណាស់ចំពោះបុគ្គលិក និងក្រុមគ្រួសារ ដើម្បីយល់ដឹងអំពីការឆ្លងរាលដាននៃជំងឺអេដស៍ និងជួយការពារទុកជាមុន"។

ការឆ្លងរាលដាលជំងឺអេដស៍បានក្លាយទៅជាបញ្ហានៃការអភិវឌ្ឍន៍ និងសេដ្ឋកិច្ចសង្គមនៅថ្នាក់ជាតិ ថ្នាក់តំបន់ ក៏ដូចជាការិតសកលលោកទាំងមូល ហើយធនាគារពិភពលោកដើរតួជាតួអង្គសំខាន់មួយ ដើម្បីប្រយុទ្ធប្រឆាំងជំងឺអេដស៍។

សំរាប់ធនាគារពិភពលោក បានចាត់ទុកថា

*តទៅពីទំព័រទី ៣*



*បុគ្គលិករបស់ធនាគារពិភពលោក និងក្រុមគ្រួសារស្តាប់ការបង្ហាញរបស់អ្នកជំនាញ*

# ដាក់រដ្ឋាភិបាលអោយនៅក្នុងដៃរបស់ប្រជាជន

*តមកពីទំព័រទី ១*

ហើយ ក្នុង ប្រវត្តិសាស្ត្រថ្មីៗនេះសំរាប់ការបោះឆ្នោតរដ្ឋាភិបាលថ្នាក់ក្រោម ។ វិមជ្ឈការគឺជាមធ្យោបាយ ដើម្បីកែលំអអភិបាលកិច្ចមូលដ្ឋាន ដែលមានកម្មវត្ថុធ្វើអោយមានគណនេយ្យភាព និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល ដើម្បីបំពេញតំរូវការរបស់ប្រជាជននៅមូលដ្ឋាន ។ ដូច្នេះ វិមជ្ឈការគឺជាមធ្យោបាយដើម្បីទទួលបាននូវកម្មវត្ថុនៃការកែលំអអភិបាលកិច្ចមូលដ្ឋាន ប៉ុន្តែវិមជ្ឈការមិនបានធានា ជាចាំបាច់ក្នុងការកែលំអអភិបាលកិច្ចមូលដ្ឋានទេ។

*សំនួរ: ហេតុអ្វីបានជាវាមានសារៈសំខាន់ក្នុងការធ្វើអោយប្រសើរសំរាប់អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា? ហេតុអ្វីបានជាយើងត្រូវការវា?*

ចំលើយ: ចា៎ស វាមានសារៈសំខាន់ណាស់ដើម្បីកែលំអអភិបាលកិច្ចមូលដ្ឋាន ដែលវាអាចនាំអោយវិស័យសាធារណៈមានការទទួលខុសត្រូវថែមទៀតសំរាប់សង្គមស៊ីវិល ហើយបំពេញតំរូវការនៅសហគមន៏។ វាមានសារៈសំខាន់សំរាប់ការអភិវឌ្ឍ ដែលរដ្ឋាភិបាល មូលដ្ឋានមានសមត្ថភាពដើម្បីទទួលខុសត្រូវ នូវតំរូវការរបស់ប្រជាជន។ បន្ទាប់ពីប្រទេស បានបញ្ចប់ជំលោះ អភិបាលកិច្ចត្រូវបានចុះថយពីព្រោះក្នុងអំឡុងពេលសង្គ្រាម រដ្ឋាភិបាលទន់ខ្សោយទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ តំរូវការចាំបាច់នៅពេលដែលរដ្ឋាភិបាលកំពុងតែធ្វើកំណែទំរង់នៅឯថ្នាក់ជាតិគឺអាចឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាជននៅខាងក្រៅទីក្រុង ពីព្រោះតំរូវការនេះមានក៏រិត។ វាមានសារៈសំខាន់ណាស់សំរាប់កម្ពុជាក៏ដូចជាប្រទេសដ៏ទៃទៀតដែរ ដើម្បីអភិវឌ្ឍសមត្ថភាព និងលទ្ធភាពនៅឯថ្នាក់មូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតំរូវការមូលដ្ឋាន។ ជាពិសេសការធ្វើការលើការកែលំអអភិបាលកិច្ចមូលដ្ឋាន មានន័យថាធ្វើយ៉ាងណាអោយរដ្ឋាភិបាលមូលដ្ឋានឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាជន មានតម្លាភាព និងបំរើអោយសហគមន៏ ធ្វើ យ៉ាងណាអោយការប្រើប្រាស់មូលនិធិសាធារណៈមានភាពប្រសើរ និងមានលទ្ធភាពខ្ពស់ និងធ្វើយ៉ាងណាអោយមានគណនេយ្យភាព នៅថ្នាក់រដ្ឋាភិបាលមូលដ្ឋានសំរាប់ការប្រើប្រាស់មូលនិធិនេះ។ វាមានសារៈ សំខាន់ណាស់សំរាប់ប្រទេសកម្ពុជាពីព្រោះកម្ពុជា មានធនធានថវិកា មានក៏រិត និងត្រូវការដាក់ធនធាន ទាំងនោះអោយដំណើរការល្អ មានប្រសិទ្ធភាពខ្ពស់ និងការប្រើប្រាស់សមរម្យ។

*សំនួរ: ខ្ញុំដឹងថា លោកស្រីកំពុងតែធ្វើការលើគំរោងមួយហៅថា គំរោងវិនិយោគទុនជនបទ និងអភិបាលកិច្ចមូលដ្ឋាន ដែលគាំទ្រថវិកាដោយធនាគារពិភពលោក។ សូមលោកស្រីមេត្តាពន្យល់អំពីការងារគំរោងនេះ និងថាតើវាអាចជួយកម្ពុជាយ៉ាងណា?*



***លោកស្រី លូ ស្គូរ៉ា : វិមជ្ឈការគឺជាមធ្យោបាយដើម្បីទទួលបានកម្មវត្ថុនៃការកែលំអអភិបាលកិច្ចមូលដ្ឋាន***

ចំលើយ: គំរោងនេះមានទឹកប្រាក់ទាំងអស់ចំនួន ៦៩.១៦ លានដុល្លា ដែលក្នុងនោះមាន ២២ លានដុល្លា ជាថវិកាបាន មកពីកម្ចីធនាគារពិភពលោក និងទឹកប្រាក់ នៅសល់បានមកពីអ្នកគាំទ្រផ្សេងៗដូចជា UNDP, DFID, SIDA និង រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងចំណោមទឹកប្រាក់ ២២ លានដុល្លា ១៩ លានដុល្លា ជួយការចំណាយរបស់រដ្ឋាភិបាលប្រចាំឆ្នាំ លើមូលនិធិឃុំ សង្កាត់ពីឆ្នាំ ២០០៣ ដល់ ឆ្នាំ ២០០៦ ដែលផ្ទេមូលនិធិពីរដ្ឋាភិបាលជាតិទៅអោយរដ្ឋាភិបាលថ្នាក់មូលដ្ឋាន។ មូលនិធិឃុំសង្កាត់ចំណាយទៅលើប្រាក់បៀវត្សរបស់ក្រុមប្រឹក្សាឃុំ និងចំណាយរដ្ឋបាល និងចំណាយលើគំរោងអភិវឌ្ឍន៏ក៏រិតមូលដ្ឋាន។ ឆ្នាំ ២០០៤ ថវិការបស់ឃុំសង្កាត់មាន ៥០ ពាន់លានរៀល ប្រមាណជា ១២.៥ លានដុល្លា ឬប្រមាណជាមធ្យមពី ៦០០០ ដុល្លា ទៅ ៨០០០ ដុល្លាសំរាប់ឃុំនីមួយៗអាស្រ័យទៅលើចំនួនប្រជាជន និងក៏រិតនៃភាពក្រីក្រ។ ដើម្បីសំរេចលើការប្រើប្រាស់មូលនិធិនេះ

*តទៅទំព័រទី ៤*



***សមាជិកក្រុមប្រឹក្សាឃុំពិនិត្យគុណភាពផ្លូវលំជនបទនៅខេត្តបន្ទាយមានជ័យ***



*លោក ម៉ក់ ថូល បុគ្គលិកធនាគារពិភពលោកម្នាក់ ដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះពិនិត្យការបង្ហាញអំពីការប្រើប្រាស់ស្រោមអនាម័យប្រកបដោយសុវត្ថភាព*

# បុគ្គលិកធនាគារពិភពលោកទទួលការបណ្តុះបណ្តាលអំពីជំងឺអេដស៍

*តមកពីទំព័រទី ១*

ជំងឺអេដស៍ជាបញ្ហារារាំងដល់ការអភិវឌ្ឍន៏ និងបញ្ហាការងារ។ ប្រធានធនាគារពិភពលោក លោក ជីម ឌី ហ្វូលហ្វិនសុន បានសន្យាក្នុងនាមជាអ្នកគ្រប់គ្រងដែលធ្វើការដើម្បីប្រឆាំងនៅនឹងជំងឺអេដស៏ដើម្បីឈានទៅរកប្រធានបទមួយ ដែលថាគ្មានបុគ្គលិកធនាគារពិភពលោក ឬក្រុមគ្រួសាររបស់គេ គួរស្លាប់ដោយសារជំងឺអេដស៏ទៀតនោះទេ។

ធនាគារពិភពលោកមានគោលការណ៏ច្បាស់លាស់ក្នុងការមិនរើសអើង ការរក្សាការសំងាត់ និងការផ្តល់ការថែ ទាំព្យាបាលដោយរួមទាំងប្រើប្រាស់ថ្នាំ និងការជំលៀសប្រសិនបើមានការចាំបាច់។

ជំងឺអេដស៏ មានបញ្ហាមួយរួចទៅហើយសំរាប់បុគ្គលិកធនាគារពិភពលោក។ នាយកដ្ឋានសេវាសុខភាព បានប៉ាន់ប្រមាណថា មានបុគ្គលិករបស់ធនាគារពិភពលោក និងក្រុមគ្រួសារ ចំនួន ៤00 នាក់ហើយដែលមានផ្ទុកវិរុសអេដស៏នៅទូទាំងពិភពលោក។ មានបុគ្គលិកនិងក្រុមគ្រួសារតិចតួចបានប្រើប្រាស់ធនធាន និងអត្ថប្រយោជន៏ របស់ធនាគារដើម្បីប្រឆាំងនិងជំងឺនេះ។ មានរបៀបវារៈពីរដែលត្រូវជំរុញសំរាប់ធនាគារពិភពលោក គឺការការពារ និងការថែទាំ។

អ្នកស្រី ទេព ស្រីពៅ បុគ្គលិករបស់ធនាគារពិភពលោក និងជាអ្នកបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ បានប្រាប់អោយដឹងថា ធនាគារពិភពលោកគឺជាស្ថាប័នល្អមួយដែលផ្តល់វគ្គបណ្តុះបណ្តាលបែបនេះ ដល់បុគ្គលិក និងក្រុមគ្រួសាររបស់គេ ហើយវាមានសារសំខាន់ណាស់ដែលអ្នកទាំងអស់គ្នាគួតែយល់ដឹងអំពីជំងឺនេះ។

អ្នកស្រីមានប្រសាសន៏ថា "បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលនេះ ខ្ញុំមានការយល់ដឹងច្រើនអំពីជំងឺអេដស៏ និងការឆ្លងរាលដាលរបស់វា ការការពារ ការប្រើប្រាស់ស្រោមអនាម័យ និងផលប្រយោជន៏ដ៏សំខាន់ ចំពោះការប្រើប្រាស់ស្រោមអនាម័យ"។ អ្វីដែលសំខាន់ទៀតនោះគឺការយល់ដឹង អំពីសារៈសំខាន់នៃការទៅពិនិត្យឈាម តាមរយៈការស្ម័គ្រចិត្តនិងមានការប្រឹក្សា និងភាពគ្រោះថ្នាក់នៃអ្នកជំងឺដែលលាក់ អាថ៌កំបាំងទុក។ ខ្ញុំយល់ឃើញថា ធនាគារពិភពលោកមានគោលនយោបាយល្អក្នុងការថែទាំបុគ្គលិកដែលឆ្លងជំងឺអេដស៏។"

លោកស្រី នីសា អាក្រាវ៉ាល ប្រធានគ្រប់គ្រងធនាគារពិភពលោកនៅកម្ពុជា បានជំរាប់អ្នកចូលរួមថា ការបណ្តុះបណ្តាលនេះមានសារៈសំខាន់ណាស់សំរាប់បុគ្គលិក និងក្រុមគ្រួសាររបស់គេ ពីព្រោះថា ប្រទេសកម្ពុជាអាត្រាអ្នករងគ្រោះដោយជំងឺអេដស៏មានកំរិតខ្ពស់។

លោកស្រីមានប្រសាសន៏ដោយសង្កត់ធ្ងន់ថា "អ្នកទាំងអស់គ្នាគួរដឹងថាប្រសិនបើបុគ្គលិករបស់ខ្លួនមានផ្ទុកជំងឺនេះ ធនាគារពិភពលោក មិនបានបញ្ឈប់ការងារគេនោះទេ។ យើងជាស្ថាប័នមួយដែលមានការថែទាំបុគ្គលិកដែលមានជំងឺនេះ។"

អ្នកស្រី ស្រីពៅក៏បានធ្វើការសរុបមកវិញដោយខ្លីថា "យើងដែលជាអ្នកបានចូលរួមគួរយកការយល់ដឹងនេះដាក់ជាប់នឹងខ្លួន និងប្រើប្រាស់វាសំរាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់យើង។

*ព័ត៌មានបន្ថែម សូមទាក់ទង*
*លោក បេង ស៊ីមេត*
*មន្ត្រីអភិវឌ្ឍន៏ធនធានមនុស្ស*
**Email: huotchea@worldbank.org**

# ដាក់រដ្ឋាភិបាលអោយនៅក្នុងដៃរបស់ប្រជាជន



*សមាជិកក្រុមប្រឹក្សាឃុំសំបូរ ខេត្តតាកែវ បង្ហាញផែនទីអភិវឌ្ឍឃុំជូនមន្ត្រីធនាគារពិភពលោកដែលបានទៅទស្សនកិច្ចនាពេលថ្មីៗកន្លងមក*

*តមកពីទំព័រទី ២*

ជារាងរាល់ ឆ្នាំដោយមានការជួយពីគណៈកម្មការផែនការ និងថវិកាដែលជាតំណាងពីប្រជាជន ក្រុមប្រឹក្សាឃុំពិនិត្យ លើផែនការមូលដ្ឋាន ហើយកំណត់អាទិភាពសំរាប់ការអភិវឌ្ឍនៅថ្នាក់ឃុំសង្កាត់។ ក្នុងកំឡុងពេល២ឆ្នាំដំបូងនៃកិច្ចប្រតិបត្តិរបស់ខ្លួនលើមូនិធិនេះ ឃុំសង្កាត់បានកំណត់ថា កិច្ចការអាទិភាពរបស់ពួកគាត់គឺហេដ្ឋារចនាសម្ព័ន្ធ ជនបទជាគន្លឹះមានជាអាទិ៍: ផ្លូវថ្នល់ លូទឹក អណ្តូងទឹក ការផ្គត់ផ្គង់ទឹក អនាម័យ ធារាសាស្រ្តខ្នាតតូច ការសាងសង់សាលា និងក្លីនិក។ ក្រុមប្រឹក្សាឃុំសង្កាត់ បានកំណត់ថាត្រូវប្រើប្រាស់ ដំណើរការដេញថ្លៃ និងផ្តល់កិច្ចសន្យានៅថ្នាក់ឃុំ។

វាមានការសង្ឃឹមថា គំរោងនេះអាចចូលរួម ការអភិវឌ្ឍជនបទ និងកាត់បន្ថយភាពក្រីក្រដោយធ្វើអោយប្រសើដល់ការរស់នៅរបស់សហគមន៍នៅជនបទ តាមរយៈការទទួលបានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ទឹកស្អាត និងអនាម័យ និងសេវាអប់រំ និងសុខភាព ។ យើងរំពឹងថាការរស់នៅរបស់ប្រជាជននិងមានលក្ខណៈប្រសើរដោយមានធនធាន នៅទីនោះដូចជាប្រព័ន្ធធារាសាស្រ្ត និងធ្វើអោយប្រសើរចំពោះសេវាទីផ្សារ។ យើងសង្ឃឹមថាគំរោងនេះអាចជួយចូលរួមដើម្បីកែលំអអភិបាលកិច្ចមូលដ្ឋាន ប៉ុន្តែគាំទ្រការធ្វើសមាហរណកម្មនិងការអនុវត្តនៃកិច្ចការគន្លឹះសំរាប់ប្រព័ន្ធវិមជ្ឈការនៅក្នុងស្ថាប័នរចនាសម្ព័ន្ធរដ្ឋាភិបាលមូលដ្ឋាន។ ការអភិវឌ្ឍផែនការ ថវិកា ប្រព័ន្ធគណនី និងសវនកម្មនៅថ្នាក់មូលដ្ឋាន។

*សំនួរ: តើគំរោងនេះ និងកម្មវិធីសីលាបំពេញគ្នាយ៉ាងដូចម្តេច?*

ចំលើយ: ការកែទំរង់វិមជ្ឈការ មានសុពលភាពតាំងពីឆ្នាំ ២០០២ នៅក្នុងការបោះឆ្នោតឃុំសង្កាត់លើកដំបូង។ គំរោងវិមជ្ឈការគឺបានសាកល្បងតាមរយៈកម្មវិធីសីលា ដោយដំណើរការសាកល្បង និងដំណើរការថវិកាដោយថ្នាក់ឃុំ និងថ្នាក់ជាតិធ្វើការជាមួយគ្នា។ នៅផ្នែកដ៏ធំនៃការសាកល្បងក្នុងកម្មវិធីសីលានេះ បច្ចុប្បន្នបានឆ្លុះបញ្ចាំងដោយផ្ទាល់ ដូចជាច្បាប់ បទបញ្ញត្តិផ្សេងៗសំរាប់កំណែទំរង់វិមជ្ឈការ។ ដូច្នេះបទពិសោធន៍ និងមេរៀនពីកម្មវិធីសីលា បានប្រើប្រាស់ដោយផ្ទាល់នៅក្នុងបរិបទរបស់វិមជ្ឈការ។ កម្មវិធីសីលា នៅតែមានតួនាទីយ៉ាងសំខាន់ នៅក្នុងការបន្តធ្វើការលើគោលការណ៍ច្បាប់ សំរាប់បង្ហូរធនធានរបស់អ្នកផ្តល់ជំនួយ និងសំរបសំរួលសកម្មភាពរបស់ក្រសួងពាក់ព័ន្ធទាំងអស់ នៅក្នុងការអនុវត្តកំណែទំរង់វិមជ្ឈការ។ លេខាធិការដ្ឋានកម្មវិធីសីលាជាភ្នាក់ងារអនុវត្តសំរាប់ការគាំទ្ររបស់ធនាគារពិភពលោក លើវិមជ្ឈការតាមរយៈគំរោងនេះ។ កម្មវិធីសីលា មិនអនុវត្តអនុគំរោងដែលធនាគារពិភពលោកផ្តល់ថវិកានោះទេ។ ប៉ុន្តែបានដើរតួជាអ្នកសំរបសំរួលការចំណាយពីធនាគារតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារ។

*សំនួរ: តើគំរោងនេះខុសគ្នា និងគំរោងដែលគាំទ្រថវិកាដោយធនាគារពិភពលោកឯទៀតដូចម្តេច?*

ចំលើយ: គំរោងនេះយើងហៅថាកម្មីវិនិយោគជាក់លាក់ ពីព្រោះថវិកាចំណាយទៅលើការវិនិយោគជាក់លាក់ ជាងការគាំទ្រជាទូទៅលើថវិការបស់រដ្ឋាភិបាល។ នៅក្នុងន័យនេះវាជាគំរោងជាក់លាក់មួយ។ គំរោងនេះជាគំរោងដែលគាំទ្រដោយ IDA និងគាំទ្រការអនុវត្តកំណែទំរង់វិមជ្ឈការដែលវានិងជាបទពិសោធន៍មួយរបស់IDA និងរដ្ឋាភិបាល។

***តទៅពីទំព័រទី ៥***

# កម្មវិធីជំនួយខ្នាតតូចផ្ដល់ទឹកប្រាក់ ៤ម៉ឺនដុល្លា ដល់អង្គការចំនួន ៦

នេះជាឆ្នាំទី ៣ ហើយដែលកម្មវិធីជំនួយខ្នាតតូច SmGP របស់ធនាគារពិភពលោកមានវត្តមាននៅកម្ពុជា។ ជំនួយខ្នាតតូចនេះបានផ្ដល់ប្រាក់ ចំនួន ៤០ ០០០ ដុល្លាអោយទៅអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ៦ ដែលធ្វើការដើម្បីគាំទ្រដល់អ្នកដែលងាយរងគ្រោះ។

SmGPបានបង្កើតឡើងនៅឆ្នាំ ១៩៨៣ ដើម្បីផ្ដល់ជាមធ្យោបាយមួយសំរាប់ធនាគារពិភពលោកជំរុញការ ពិភាក្សានិងការផ្សព្វផ្សាយព័ត៌មានអំពីការងារអភិវឌ្ឍន៍អន្តរជាតិនៅក្នុងវេទិកាក្រៅពីកិច្ចការប្រតិបត្តិរបស់ខ្លួន។ សំរាប់ប្រទេសកម្ពុជា SmGP បានចាប់ផ្ដើមឆ្នាំ ២០០២។ ឆ្នាំនេះ បានផ្ដល់ដល់អង្គការចំនួន ៦ រួមមាន: យែនឌ័រ និងអភិវឌ្ឍន៍នៅកម្ពុជា (GAD/C) យុវសន្តិភាព (YFP) អង្គការកុមារកំព្រានៅបាត់ដំបង (OEB) អង្គការដៃគូរកសិករ (DKK) បណ្ដាញតស៊ូមតិនៅកំពង់ចាម (K-NAN) និងអង្គការពុទ្ធសាសនាសំរាប់ការអភិវឌ្ឍ (BFD)។

អង្គការ GAD/C គឺជាអ្នកទទួលបានជំនួយនេះជាលើកទី ២ ដែលមានទឹកប្រាក់ចំនួន ៨ ០០០ ដុល្លា ដើម្បីផ្ដល់ការបណ្ដុះបណ្ដាល ការលើកកំពស់អំណាចស្ត្រីតាមរយៈការផ្ដល់ការយល់ដឹងអំពីច្បាប់ ដល់ក្រុមបង្គោលនៅក្នុងភូមិ និងពង្រីកចំណេះដឹងនេះទៅដល់បណ្ដាញរបស់គេដែលធ្វើការនៅ ៧ ឃុំ និង បោះពុម្ពប័ណ្ណផ្សព្វផ្សាយ និងឯកសារដែលទាក់ទង និងច្បាប់សំរាប់ថ្នាក់ឃុំ និងជួយក្នុងការបង្កើតបណ្ណាល័យ និងផ្ដល់ឯកសារផ្សេងៗដល់ឃុំទាំងនោះ។ សកម្មភាពនេះនិងធ្វើឡើងនៅខេត្ត កំពង់ស្ពឺ កំពង់ឆ្នាំង និងពោធិសាត់។

ជាមួយនឹងទឹកប្រាក់ ៧ ៥០០ ដុល្លា អង្គការយុវសន្តិភាព និងរៀបចំកម្មវិធី សន្តិភាពសិក្ខាសាលាអំពីយុវជន និងភាពជា អ្នកដឹកនាំ គាំទ្រការសំរបសំរួលគំនិត ផ្ដួចផ្ដើមថ្មីៗ ប្រារព្ធការជួបជុំគ្នារបស់យុវជន មួយនៅភ្នំពេញ និងការជួបជុំយុវជនថ្នាក់ជាតិ និងប្រារព្ធធ្វើឡើងនៅខេត្តកំពង់ឆ្នាំង។

អង្គការ OBE ក៏ជាអង្គការមួយដែលបានទទួលជំនួយនេះជាលើកទី ២ ដែរ ប៉ុន្តែឆ្នាំនេះទទួលបានទឹកប្រាក់ចំនួន ៨ ៥០០ ដុល្លា ដើម្បីបន្តការងារលើការជួយកុមារនៅក្នុងតំបន់ដែល ទើបបញ្ចប់ជំលោះនៅក្នុងស្រុកកោះក្រឡ ខេត្តបាត់ដំបង និង នៅក្នុងខេត្តបន្ទាយមានជ័យ ដូចជាការធ្វើសិក្ខាសាលាស្ដីអំពីសិទ្ធិកុមារ អនាម័យ អនក្ខរភាព និងអាហារូបត្ថម្ភ។

កម្មវិធីជំនួយខ្នាតតូចក៏បានផ្ដល់ទឹកប្រាក់ចំនួន ៥ ៥០០ ដុល្លា ដល់អង្គការដៃគូកសិករ ដែលជាអង្គការមួយនៅខេត្តកំពង់ធំ។ ជាមួយនិងទឹកប្រាក់ជំនួយនេះ

តទៅទំព័រទី ៦

# ដាក់រដ្ឋាភិបាលអោយនៅក្នុងដៃរបស់ប្រជាជន

តមកពីទំព័រទី ៤

ទីមួយគឺផ្ដោតជាសំខាន់ទៅលើភាពជាដៃគូ និងជំរុញឆ្ពោះទៅរកផ្នែកទូទៅមួយដោយជួយបង្កើនការគាំទ្រថវិកាពីម្ចាស់ជំនួយដែលមានស្រាប់លើគំរោងដែលដឹកនាំដោយរដ្ឋាភិបាល។ ទីពីរ គឺការជំរុញឆ្ពោះទៅរកការគាំទ្រដោយ IDA និងវិធានការថវិកានៅក្នុងស្តង់ដារដែលស្របទៅនិងមូលនិធិឃុំសង្កាត់ ហើយវាមិនមែនតែផ្នែកថវិការបស់IDAទេ។ ទី៣ ច្បៀសវាងរចនាសម្ព័ន្ធគំរោងដាក់លាក់ជាមួយនឹងការរៀបចំការអនុវត្ត ជាមួយនឹងរចនាសម្ព័ន្ធ និងស្ថាប័នដែលមានស្រាប់ ទាមទារអោយមានការចូលរួមពីក្រសួងនានា ដូចជា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំណែកក្រសួងអភិវឌ្ឍន៍ជនបទ ផ្ដល់ការគាំទ្រផ្នែកបច្ចេកទេស ហើយមានការសំរបសំរួលលើសកម្មភាពទាក់ទងគ្នាទាំងបីផ្នែកមានថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ឃុំសង្កាត់។

*សំនួរ: តើសារសំខាន់ៗអ្វីខ្លះដែលលោកស្រីចង់ជំរាបជូនប្រជាជនកម្ពុជាដើម្បីអោយគាត់យល់អំពីបញ្ហាទាំងនេះ?*

ចំលើយ: ខ្ញុំគិតថាដោយសាប្រជាជនកម្ពុជាភាគច្រើនរស់នៅតាមជនបទពួកគាត់បានស្គាល់បញ្ហាទាំងនេះហើយ។ វាមានលក្ខណៈងាយស្រួលសំរាប់ប្រជាជនកម្ពុជាសំរាប់យល់ដឹងអំពីបញ្ហាទាំងនេះ និងការនាំយករដ្ឋាភិបាលអោយទៅជិតពួកគាត់ ហើយទាមទារអោយមានការឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាជន។ អ្វីដែលពួកគាត់មិនទាន់យល់នោះគឺតួនាទីដ៏សំខាន់របស់ពួកគាត់ដែលទាមទារអោយមានសេវាប្រសើរដោយចូលរួមក្នុងដំណើរការ និងធ្វើយ៉ាងណាអោយសំលេងពួកគាត់បានឮ និងអោយមានការទទួលខុសខ្ពស់ ដើម្បីបំរើតំរូវការរបស់ប្រជាជនពីរដ្ឋាភិបាលមូលដ្ឋាន។ ពួកគាត់គួរដឹងផងដែរថាធនាគារពិភពលោកមានការប្ដេជ្ញា ដើម្បីគាំទ្រការអនុវត្តវិមជ្ឈការជួយធ្វើយ៉ាងណាអោយការសន្យាកើតមានឡើងពិតប្រាកដដូចជាធ្វើអោយប្រសើរលើអភិបាលកិច្ចមូលដ្ឋាន និងលើកកំពស់ការផ្ដល់សេវា។

*សំនួរ: តើការចូលរួមរបស់រដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិលនៅក្នុងបញ្ហានេះយ៉ាងដូចម្ដេចដែរ?*

ចំលើយ: តាមរយៈកំណែទំរង់វិមជ្ឈការ រដ្ឋាភិបាលថ្នាក់ជាតិបានធ្វើប្រតិភូកម្មអំណាចនយោបាយនិងការទទួលខុសត្រូវសំរាប់ការផ្ដល់សេវា និងការងារទៅអោយថ្នាក់ឃុំសង្កាត់។ សង្គមស៊ីវិល ចូលរួមជាគោលការណ៍តាមរយៈគណៈកម្មាការផែនការ និងថវិកានៅក្នុងដំណើរការ ប្រជុំនិងរៀបចំផែនការ។ វិស័យឯកជនចូលរួមផ្ទាល់នៅក្នុងការដេញថ្លៃប្រកបដោយការប្រកួតប្រជែងក្នុងលក្ខណៈមានតម្លាភាព និងដំណើរការប្រកួតប្រជែងសំរាប់កិច្ចសន្យានានា។



*លោកស្រី រស់ សុភាព នាយកប្រតិបត្តិ អង្គការយែនឌ័រដើម្បីអភិវឌ្ឍន៍នៅកម្ពុជា ដែលជាអង្គការមួយ ក្នុងចំណោមអង្គការទាំង៦ដែលទទួលបានជំនួយខ្នាតតូចពីធនាគារពិភពលោក ពន្យល់ពីការប្រើប្រាស់ជំនួយនេះ*

# កម្មវិធីជំនួយខ្នាតតូចផ្តល់ទឹកប្រាក់ ៤ម៉ឺនដុល្លា ដល់អង្គការចំនួន ៦

***តមកពីទំព័រទី ៤***

អង្គការនិងប្រើប្រាស់សំរាប់រៀបចំសិក្ខាសាលានៅថ្នាក់ភូមិស្តីអំពីគ្រប់គ្រងបែបរិមជ្ឈការ ការយល់ដឹងអំពីយែនឌ័រ និងគាំទ្រជនបង្គោលក្នុងភូមិដើម្បីចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំលើផែនការអភិវឌ្ឍន៍នានា។ ក្រៅពីសិក្ខាសាលា កម្មវិធីនេះនិងរៀបចំការជួបជុំគ្នាមួយរវាងប្រជាជន ក្រុមប្រឹក្សាឃុំ និងក្រុមប្រិក្សាអភិវឌ្ឍន៍ភូមិ ដើម្បីចែករំលែកបទពិសោធន៍ការងារ និងការឆ្លុះបញ្ចាំងឡើងវិញមេរៀនដែលបានរៀនកន្លងមក។

បណ្តាញតស៊ូមតិខេត្តកំពង់ចាម ក៏ទទួលបានទឹកប្រាក់ចំនួន ៥ ៥០០ ដុល្លាដែរ ដើម្បីរៀបចំវេទិការសាធារណៈមួយស្តីអំពីបញ្ហាដីធ្លីនៅក្នុងស្រុកគោលដៅចំនួន ៧ របស់ខេត្តកំពង់ចាម។

ជាមួយនឹងទឹកប្រាក់ ៥០០០ ដុល្លាអង្គការព្រះពុទ្ធសាសនាសំរាប់ការអភិវឌ្ឍ និងប្រើប្រាស់ដើម្បីបង្កើតជាយន្តការ មួយសំរាប់ការចូលរួមលើកកំពស់សន្តិភាព និងការអភិវឌ្ឍតាមរយៈការធ្វើសិក្ខាសាលាដើម្បីបង្កើនការយល់ដឹង និងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំលើវិមជ្ឈការ សិទ្ធិមនុស្ស និងដំណោះស្រាយជំលោះ។

លោកស្រី និល វណ្ណា មន្ត្រីសំរបសំរួលកម្មវិធីនេះ មានប្រសាសន៍ថា ឆ្នាំនេះកម្មវិធីជំនួយខ្នាតតូចរបស់ធនាគារពិភពលោក បានផ្តល់អោយអង្គការមិនមែនរដ្ឋាភិបាល ដែលនិងធ្វើសកម្មភាពនៅថ្នាក់ឃុំសង្កាត់ ដោយរាប់ចាប់តាំងពីរាជធានី ភ្នំពេញ ខេត្តកំពង់ធំ កំពង់ចាមកំពង់ស្ពឺ ព្រៃវែង សៀមរាប កំពង់ឆ្នាំង បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ និងខេត្តតាកែវ ។

លោកស្រីមានប្រសាសន៍ថា "កម្មវិធីនេះបានផ្តល់ឱកាសសំរាប់ការលើកកំពស់ការពិភាក្សា និងបង្កើនសមត្ថភាពដល់សមាជិកក្រុមប្រឹក្សាឃុំ ផ្តល់សំលេងដល់ប្រជាជនក្រីក្រដើម្បីបញ្ចេញនូវគំនិតរបស់គេ និងការព្រួយបារម្ភដែលទាក់ទងទៅនិងការអភិវឌ្ឍមូលដ្ឋាន។ លោកស្រីបន្តថា "កម្មវិធីនេះក៏បានជួយផងដែរដើម្បីកែលំអតម្លាភាព គណនេយ្យភាព និងការធ្វើជាម្ចាស់នៅមូលដ្ឋាន"។

**ព័ត៌មានបន្ថែម សូមទាក់ទង**
**លោកស្រី និល វណ្ណា**
***Email: vnil@worldbank.org***

យើងខ្ញុំសូមស្វាគមន៍ការផ្តល់មតិ និងយោបល់ផ្សេងៗ សូមផ្ញើលិខិតមតិយោបល់ និងសំណួរ ទាំងនោះមក លោក **ប៊ូ សារឿន** ឯកទេស ទំនាក់ទំនងព័ត៌មានធនាគារពិភព លោក ការិយាល័យ នៅកម្ពុជា ផ្ទះលេខ ១១៣ មហាវិថីព្រះនរោត្តម
អ៊ីម៉ែល៖ sbou@worldbank.org